00949943

E138/1/10/1/5/9

សាធារណៈ / Public

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 01 / 10 / 2013
ម៉ោង (Time/Heure): 09:40
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១៣

ជូនចំពោះ៖ អង្គភាពគាំពារសាក្សី និងអ្នកជំនាញ,
ការិយាល័យរដ្ឋបាល

ពី៖ ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

ចម្លងជូន៖ ភាគីនៃសំណុំរឿង ០០២, លោក /លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់ នៃអង្គជំនុំជម្រះសាលាដំបូង, អាណាព្យាបាលស្របច្បាប់របស់ អៀង ធីរិទ្ធ

កម្មវត្ថុ៖ ការតែងតាំងវេជ្ជបណ្ឌិតដើម្បីអនុវត្តការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រលើ អៀង ធីរិទ្ធ រៀងរាល់ប្រាំមួយខែម្តង

១. កាលពីថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២ អង្គជំនុំជម្រះតុលាការកំពូល បានបង្គាប់ឲ្យជនជាប់ចោទ អៀង ធីរិទ្ធ "ទទួលការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្ររៀងរាល់ប្រាំមួយខែម្តង ដោយអ្នកជំនាញផ្នែកវេជ្ជសាស្ត្រដែលត្រូវបានតែងតាំងដោយអង្គជំនុំជម្រះសាលាដំបូង" (ឯកសារ E138/1/10/1/5/7 )។ តបទៅនឹងសំណើសុំការបញ្ជាក់បំភ្លឺរបស់មេធាវីការពារក្តី អៀង ធីរិទ្ធ កាលពីថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៣ អង្គជំនុំជម្រះតុលាការកំពូលបានគូសបញ្ជាក់ថា "ការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្ររៀងរាល់ប្រាំមួយខែនោះ គឺក្នុងគោលបំណងត្រួតពិនិត្យជាទៀងទាត់ទៅលើបញ្ហាដែលនាំឲ្យមានការសម្រេចថា អៀង ធីរិទ្ធ ពុំមានសម្បទាគ្រប់គ្រាន់

ក្នុងការចូលរួមសវនាការ ដែលសំដៅលើស្ថានភាពសតិបញ្ញាចុះខ្សោយរបស់ជនជាប់ចោទ [...] ការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រមានគោលដៅបញ្ជាក់ថាតើស្ថានភាពសតិបញ្ញារបស់ អៀង ធីរិទ្ធ មានភាពប្រសើរឡើង ឬថយចុះ ព្រមទាំងធ្វើការវាយតម្លៃពីតម្រូវការក្នុងការព្យាបាល។ មិនមានមូលដ្ឋានសមស្របណាមួយសម្រាប់ទាញសន្និដ្ឋានថាការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រ ត្រូវធ្វើឡើងហួសពីគោលដៅនេះឡើយ" (E138/1/10/1/5/8/2, កថាខណ្ឌ ១១)។

២. កាលពីថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១៣ អង្គជំនុំជម្រះបានចេញដីកាមួយដែលរៀបរាប់អំពីលក្ខខណ្ឌតម្រូវនៃការធ្វើរបាយការណ៍សម្រាប់អាណាព្យាបាលស្របច្បាប់របស់ អៀង ធីរិទ្ធ និងបានគូសបញ្ជាក់ថាអង្គជំនុំជម្រះនឹង "ធ្វើដីកាដាច់ដោយឡែកមួយទាក់ទងនឹងការវាយតម្លៃតាមកាលកំណត់ទៅលើ អៀង ធីរិទ្ធ អំពីមុខងារបញ្ញាស្មារតីរបស់គាត់នៅខែ កញ្ញា ឆ្នាំ ២០១៣ និងការតែងតាំងអ្នកជំនាញនាពេលសមស្របខាងមុខ" (ឯកសារ E138/1/10/1/5/8/4)។

៣. ដោយមានជំនួយពីអង្គភាពគាំពារសាក្សី និងអ្នកជំនាញ អង្គជំនុំជម្រះបានកំណត់អត្តសញ្ញាណវេជ្ជបណ្ឌិតឯកទេសវិកលវិទ្យាមួយរូបដែលមានគុណវុឌ្ឍិដើម្បីពិនិត្យជនជាប់ចោទ អៀង ធីរិទ្ធ ដោយអនុលោមតាមវិធាន ៣១ និង ៣២ នៃវិធានផ្ទៃក្នុង។ តាមរយៈនេះ អង្គជំនុំជម្រះតែងតាំងវេជ្ជបណ្ឌិត Ben VAN DEN BUSSCHE (ដោយមានជំនួយពីវេជ្ជបណ្ឌិត គឹម ចាន់ថន) ជាអ្នកជំនាញដែលមានភារកិច្ចដូចខាងក្រោម៖

ក. ពិនិត្យមើលឡើងវិញអំពីរបាយការណ៍របស់អ្នកជំនាញវេជ្ជសាស្ត្រ ដែលត្រូវបានតែងតាំងដោយអង្គជំនុំជម្រះកាលពីពេលកន្លងមក ត្រង់ចំណុចនានាពាក់ព័ន្ធនឹងស្ថានភាពផ្នែកស្មារតីរបស់ អៀង ធីរិទ្ធ និងសេចក្តីសន្និដ្ឋានរបស់អ្នកជំនាញដែលថាគាត់មានជំងឺវង្វេងស្មារតី ពីកម្រិតមធ្យមទៅធ្ងន់ធ្ងរ។

ខ. វាយតម្លៃឡើងវិញអំពីស្ថានភាពបញ្ញាស្មារតីរបស់ អៀង ធីរិទ្ធ

គ. វិនិច្ឆ័យថាតើមានការប្រសើរឡើង ឬការធ្លាក់ចុះនៃស្ថានភាពរបស់គាត់ ហើយថាតើការព្យាបាលណាមួយនៃស្ថានភាពបញ្ញាស្មារតីរបស់គាត់ ត្រូវបានណែនាំដែរឬយ៉ាងណា។

៤.	មុនពេលអនុវត្តភារកិច្ចនេះ អ្នកជំនាញត្រូវធ្វើសម្បថជាលាយលក្ខណ៍អក្សរ ដោយអនុលោមតាមវិធាន ៣១(២) នៃវិធានផ្ទៃក្នុង។ អ្នកជំនាញគួរកំហិតការពិនិត្យរបស់គាត់ត្រឹមស្ថានភាពបញ្ញាស្មារតីរបស់ជនជាប់ចោទ និងធ្វើរបាយការណ៍ជូនអង្គជំនុំជម្រះត្រឹមថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០១៣។

៥.	ដើម្បីជាជំនួយដល់អ្នកជំនាញនៅក្នុងការបំពេញភារកិច្ចរបស់ខ្លួន អង្គជំនុំជម្រះបង្គាប់ឲ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ប្រគល់ជូនអ្នកជំនាញនូវរបាយការណ៍របស់អ្នកជំនាញវេជ្ជសាស្ត្រដែលត្រូវបានតែងតាំងដោយអង្គជំនុំជម្រះកាលពីពេលមុន។ អង្គជំនុំជម្រះបង្គាប់ឲ្យការិយាល័យរដ្ឋបាលជួយដល់អ្នកជំនាញក្នុងករណីចាំបាច់។